## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៣៧ ក.យ.ស.ប្រក/២១

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌នៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ សរសេរជាអក្សរកាត់ថា "**ល.ក.ន.យ.**"។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693
www.moj.gov.kh

**ប្រការ២ .-**

**ល.ក.ន.យ.** បំពេញមុខងារជាសេនាធិការឱ្យក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ (**ក.ន.យ.**) លើកិច្ចការបច្ចេកទេសច្បាប់, កិច្ចការស្រាវជ្រាវ និងវិភាគ និងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈ ដូចតទៅៈ

- ជួយ **ក.ន.យ.** លើការសិក្សា ស្រាវជ្រាវ និងការលើកយោបល់បច្ចេកទេសជូនក្រសួងយុត្តិធម៌ ចំពោះរាល់ការងារដែលជាសមត្ថកិច្ចរបស់ **ក.ន.យ.** ដូចមានកំណត់ក្នុងមាត្រា២ នៃអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌
- ជួយ **ក.ន.យ.** លើការវិភាគនយោបាយ និងគោលនយោបាយផ្នែកច្បាប់ ព្រមទាំងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលអាចជាមូលដ្ឋានដល់ការអភិវឌ្ឍវិស័យច្បាប់ យុត្តិធម៌ និងអភិបាលកិច្ច
- សម្របសម្រួល និងទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **ក.ន.យ.**
- រៀបចំ និងសម្របសម្រួលកម្មវិធីការងារ កិច្ចប្រជុំ បេសកកម្ម និងពិធីការផ្សេងៗរបស់ **ក.ន.យ.**
- គ្រប់គ្រងការងារបុគ្គលិកក្នុង **ល.ក.ន.យ.**
- ទទួលបន្ទុករៀបចំ និងគ្រប់គ្រងថវិកា ទ្រព្យសម្បត្តិ បញ្ជីសារពើភណ្ឌ សន្និធិសម្ភារៈ សម្រាប់បម្រើការងារក្នុង **ក.ន.យ.**
- រៀបចំបែបបទទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងអង្គការជាតិ និងអន្តរជាតិនានា
- រៀបចំឯកសារ របាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំ និងកម្មវិធីផ្សេងៗរបស់ **ក.ន.យ.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **ក.ន.យ.**
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ក.ន.យ.**។

**ប្រការ៣ .-**

**ល.ក.ន.យ.** មានរចនាសម្ព័ន្ធ ដូចតទៅៈ

- ការិយាល័យកិច្ចការទូទៅ
- ការិយាល័យកិច្ចការច្បាប់
- ការិយាល័យកិច្ចការយុត្តិធម៌
- ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ។

អង្គការលេខរបស់ **ល.ក.ន.យ.** ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤ .-**

ការិយាល័យកិច្ចការទូទៅ មានតួនាទី និងភារកិច្ច ដូចតទៅៈ

- គ្រប់គ្រងការងាររដ្ឋបាល លិខិតចេញ-ចូល និងឯកសាររដ្ឋបាលនានា
- គ្រប់គ្រងការងារបុគ្គលិក

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិការបស់ **ល.ក.ន.យ.**
- គ្រប់គ្រងចលនវត្ថុ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌរបស់ **ក.ន.យ.**
- ទំនាក់ទំនងសម្របសម្រួលស្នើសុំថវិកា និងធ្វើរបាយការណ៍ទូទាត់ចំណូល-ចំណាយថវិកា សម្ភារៈ និងបរិក្ខារផ្សេងៗ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **ក.ន.យ.**
- រៀបចំ និងសម្របសម្រួលកម្មវិធីការងារ បេសកកម្ម និងពិធីការផ្សេងៗរបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- រៀបចំ និងសម្របសម្រួលរាល់កិច្ចប្រជុំ និងកម្មវិធីផ្សេងៗរបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- សម្របសម្រួលការងារទំនាក់ទំនងជាមួយអគ្គនាយកដ្ឋាន និងអង្គភាពផ្សេងៗចំណុះឱ្យក្រសួងយុត្តិធម៌ ការងារទំនាក់ទំនងសាធារណៈ និងការគ្រប់គ្រងបណ្តាញសង្គមរបស់ **ក.ន.យ.**
- រៀបចំ និងចងក្រងសម្រាប់ការបោះពុម្ពនូវព្រឹត្តិបត្រ និងឯកសារស្រាវជ្រាវផ្សេងៗរបស់ **ក.ន.យ.**
- រៀបចំ និងបូកសរុបផែនការការងាររបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- ធ្វើរបាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំរបស់ **ក.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ល.ក.ន.យ.**។

ការិយាល័យកិច្ចការទូទៅ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៥ .-**

ការិយាល័យកិច្ចការច្បាប់ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងលើកយោបល់ទាក់ទងនឹងសង្គតិភាព និងអនុលោមភាពគតិយុត្តនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ជាមួយនិងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សិក្សាស្រាវជ្រាវ និងលើកយោបល់ទាក់ទងនឹងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ព្រមទាំងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យយុត្តិធម៌ ជាមួយនិងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងវិស័យយុត្តិធម៌
- សិក្សាស្រាវជ្រាវ និងវាយតម្លៃអំពីផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យច្បាប់ និងយុត្តិធម៌

- ចូលរួមជាមួយអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ក្នុងការរៀបចំចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ដើម្បីផ្សព្វផ្សាយ ក៏ដូចជាការរៀបចំ និងបោះពុម្ពផ្សាយព្រឹត្តិបត្រច្បាប់ ជាដើម
- ចូលរួមរៀបចំផែនការការងាររបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ល.ក.ន.យ.**។

ការិយាល័យកិច្ចការច្បាប់ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៦ ._**

ការិយាល័យកិច្ចការយុត្តិធម៌ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីតម្រូវការក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់សម្រាប់បម្រើឱ្យវិស័យយុត្តិធម៌ និងអំពីភាពចាំបាច់នានាក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យយុត្តិធម៌
- សិក្សាស្រាវជ្រាវអំពីប្រព័ន្ធយុត្តិធម៌ និងការផ្តល់សេវាយុត្តិធម៌ ក៏ដូចជាយន្តការដោះស្រាយវិវាទនានានៅក្នុងបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីបានជាធាតុចូលក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ កិច្ចដំណើរការល្អនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅកម្ពុជា ព្រមទាំងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីតម្រូវការចាំបាច់ក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ ក៏ដូចជាកិច្ចដំណើរការនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ចូលរួមសហការតាមការចាំបាច់ជាមួយនឹងអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ សំដៅបង្កើនប្រសិទ្ធភាពនៃការគោរពច្បាប់ និងអនុវត្តច្បាប់
- ចូលរួមរៀបចំផែនការការងាររបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ល.ក.ន.យ.**។

ការិយាល័យកិច្ចការយុត្តិធម៌ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៧ ._**

ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងវិភាគអំពីនយោបាយ និងគោលនយោបាយផ្នែកច្បាប់ យុត្តិធម៌ និងអភិបាលកិច្ច

- តាមដាន ប្រមូល និងវិភាគព័ត៌មានសំខាន់ៗទាក់ទងនឹងបច្ចុប្បន្នភាព និងការវិវត្តនៃវិស័យច្បាប់ និងយុត្តិធម៌ នៅក្នុងប្រទេស តំបន់ និងពិភពលោក ដែលអាចជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីតម្រូវការចាំបាច់ ក្នុងការធ្វើបច្ចុប្បន្នភាពច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី និងវិស័យផ្សេងទៀត
- ចូលរួមរៀបចំផែនការការងាររបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ល.ក.ន.យ.**។

ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្ដាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្ដាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៨** ..

មន្ត្រីដែលបំពេញការងារនៅ **ល.ក.ន.យ.** គឺជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៅក្រសួងយុត្តិធម៌។ ក្នុងករណីចាំបាច់ ប្រធាន **ល.ក.ន.យ.** អាចស្នើសុំទៅប្រធាន **ក.ន.យ.** ដើម្បីជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារ ដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន។

**ប្រការ៩** ..

ដើម្បីបំពេញតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រកាសនេះ **ល.ក.ន.យ.** ប្រើប្រាស់ធនធានថវិកា និងហិរញ្ញវត្ថុរបស់ **ក.ន.យ.** ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌។

**ប្រការ១០** ..

នាយកខុទ្ទកាល័យ អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌នៃក្រសួងយុត្តិធម៌ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០៣៧ កយ.ប្រក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

អង្គការលេខរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌




www.moj.gov.kh